**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើស និងបញ្ជូនជនទេសន្តរប្រវេសន៍ការងារខ្មែរ នៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់សាធារណជន ជាពិសេសប្រជាពលរដ្ឋខ្មែរ ដែលមានបំណងស្វែងរកការងារធ្វើនៅក្រៅប្រទេសឱ្យបានជ្រាបថា ថ្មីៗនេះ ក្រសួងតែងកត់សម្គាល់ឃើញថាមានជនឆ្លៀតឱកាសបានផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម អំពីការសម្របសម្រួលផ្តល់សេវា និងរត់ការជួយប្រជាពលរដ្ឋខ្មែរដើម្បីទៅធ្វើការនៅក្រៅប្រទេស ដោយពុំមានការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឡើយ។

ដើម្បីធានាបាននូវការធ្វើទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាព ការការពារសិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋខ្មែរ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបញ្ជាក់អំពីយន្តការផ្លូវការដែលកំពុងអនុវត្តក្នុងការបញ្ជូនជនទេសន្តរប្រវេសន៍ការងារខ្មែរទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់មានចំនួន ២ ដូចខាងក្រោម៖

១. យន្តការបញ្ជូនតាមរយៈរដ្ឋនិងរដ្ឋ៖ យន្តការនេះត្រូវបានគ្រប់គ្រងនិងអនុវត្តផ្ទាល់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយរដ្ឋាភិបាលនៃបណ្តាប្រទេសទទួល រួមមាន៖
   - សាធារណរដ្ឋកូរ៉េ៖ វិស័យឧស្សាហកម្ម កសិកម្ម និងសំណង់
   - រដ្ឋអ៊ីស្រាអែល៖ វិស័យកសិកម្ម។

២. យន្តការបញ្ជូនតាមរយៈឯកជននិងឯកជន៖ យន្តការនេះអនុវត្តតាមរយៈទីភ្នាក់ងារផ្តល់សេវាការងារក្រៅប្រទេស ដែលទទួលបានការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បណ្តាប្រទេស ដូចខាងក្រោម៖
   - ប្រទេសជប៉ុន៖ កម្មសិក្សាការី និងពលករជំនាញ
   - ប្រទេសម៉ាឡេស៊ី៖ ផ្នែកទូទៅ និងសេវាកម្មតាមផ្ទះនិងសណ្ឋាគារ
   - ប្រទេសសិង្ហបុរី៖ ផ្នែកទូទៅ (កម្មន្តសាល សំណង់ កែច្នៃ ផលិត/ជួសជុលនាវា និងសេវាកម្ម) និងស្ត្រីជំនួយការផ្ទះ
   - តំបន់រដ្ឋបាលពិសេសហុងកុង៖ ស្ត្រីជំនួយការផ្ទះ
   - ប្រទេសវៀតណាម៖ វិស័យឧស្សាហកម្ម និងសំណង់
   - បណ្តាប្រទេសអារ៉ាប់៖ ផ្នែកបដិសណ្ឋារកិច្ច និងសណ្ឋាគារ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារៈ (០២៣)៨៨ ២៧ ៦៥

សាធារណជន អាចស្វែងរកបញ្ជីឈ្មោះបច្ចុប្បន្នភាពទីភ្នាក់ងារផ្តល់សេវាការងារក្រៅប្រទេសបានតាមរយៈគេហទំព័រផ្លូវការរបស់ក្រសួងតាមរយៈតំណភ្ជាប់ www.mlvt.gov.kh ឬកម្មវិធីទូរសព្ទដៃរបស់ក្រសួង "**MLVT Services**" ឬតាម "**បញ្ជរសេវាសាធារណៈចល័តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**" និងតាមរយៈតំណភ្ជាប់ https://tracking.ocwc.co/។

ដើម្បីចៀសវាងការធ្លាក់ខ្លួនជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ក្រសួងសូមក្រើនរំលឹកដល់សាធារណជន និងប្រជាពលរដ្ឋខ្មែរដែលមានបំណងទៅធ្វើការនៅក្រៅប្រទេសត្រូវៈ

១. ស្វែងយល់ឱ្យបានច្បាស់លាស់អំពីនីតិវិធីទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់។

២. មិនត្រូវជឿលើការឃោសនាបោកប្រាស់របស់មេខ្យល់ ឬបុគ្គលដែលអះអាងថាអាចបញ្ជូនទៅធ្វើការនៅក្រៅប្រទេសបានលឿន ដោយមិនបាច់ឆ្លងកាត់នីតិវិធីស្របច្បាប់។

៣. ពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះទីភ្នាក់ងារផ្តល់សេវាការងារក្រៅប្រទេសជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត។

៤. ជ្រើសរើសតែទីភ្នាក់ងារផ្តល់សេវាការងារក្រៅប្រទេសណា ដែលទទួលបានការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈតែប៉ុណ្ណោះ។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងចាត់វិធានការតាមផ្លូវច្បាប់ចំពោះបុគ្គល ឬក្រុមហ៊ុនទាំងឡាយណា ដែលផ្សព្វផ្សាយព័ត៌មានឱកាសការងារ ឬសម្របសម្រួលបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសដោយខុសច្បាប់ និងគ្មានការអនុញ្ញាតពីក្រសួង។

សម្រាប់ព័ត៌មានបន្ថែម ឬការរាយការណ៍ផ្សេងៗ សូមទំនាក់ទំនងតាមរយៈប្រព័ន្ធ Hotline លេខ ១២៩៧ ឬក្រុមតេឡេក្រាមផ្លូវការ "សម្រាប់ ពលករទេសន្តរប្រវេសន៍" (https://t.me/KhmerMigrantWorker) ដែលអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម ឬមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ដែលនៅជិតលោកអ្នក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ១០កើត ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៦

ស្វែងរកព័ត៌មានតាមរយៈ៖

១. ប្រព័ន្ធ Telegram "សម្រាប់ពលករទេសន្តរប្រវេសន៍"

២. ប្រព័ន្ធ Telegram "ស្វែងរកការងារក្រៅប្រទេស"